សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច

ការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង

៚៚៚❃៙៙៙

**គុណភាព ក្លាហាន មោះមុត**

**ក្រមសីលធម៌ និង មនសិការជាតិ**

៚៚៚❃៙៙៙

# ផែនការប្រតិបត្តិ ៣ ឆ្នាំ
# ឆ្នាំ២០១៣-២០១៦
# របស់សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច

## I- សេចក្តីផ្តើម

ក្នុងរយៈកាលជាង ១ ទសវត្សកន្លងមកនេះប្រទេសកម្ពុជា មានការអភិវឌ្ឍ និងរីកចម្រើន លើគ្រប់វិស័យនានាគួរឲ្យកត់សម្គាល់យ៉ាងខ្លាំងទាំងផ្នែករដ្ឋ និងឯកជន ដោយអនុវត្តន៍តាម យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណនេយ្យភាព និង អភិបាលកិច្ចល្អជាស្នូលក្នុងកសាងមាតុភូមិអង្គរដ៏បវររុងរឿងឲ្យមានការលូតលាស់រីកចម្រើនដូចជាប្រទេសផ្សេងៗនៅលើពិភពលោក ក្នុងបរិបទសាកលភាវូបនីយកម្មនិងសេដ្ឋកិច្ចទីផ្សារសេរី ។ ដោយក្នុងនោះដែរ វិស័យអប់រំនៅកម្ពុជា បានដើរតួយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយចីរភាពនិងជាសសៃឈាមសេដ្ឋកិច្ចរបស់សង្គមជាតិមួយពុំអាចខ្វះបាន។ ការបណ្តុះបណ្តាល ធនធានមនុស្សថ្នាក់កម្រិតឧត្តមសិក្សា ជាបុព្វហេតុដ៏ចម្បងជាងគេ ឆ្ពោះទៅរកប្រភពចលករការងារ និងភាពជាអ្នកដឹកនាំប្រកបដោយភាពវាងវៃ ក្លាហាន និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដឹកនាំនាវាកម្ពុជាទៅរកសុខសន្តិភាព និង ការអភិវឌ្ឍបន្ថែមទៀតនាពេលអនាគត ។ ដើម្បីធានាបាននូវការអប់រំមួយប្រកបដោយគុណភាព សមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងវិជ្ជាជីវៈការងាររបស់និស្សិតគ្រប់រូប ការអប់រំបណ្តុះបណ្តាលចាំបាច់ត្រូវកំណត់នូវយុទ្ធសាស្រ្តដែលមានលក្ខណៈច្បាស់លាស់ មកធ្វើជាមូលដ្ឋាន សម្រាប់អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពយូរអង្វែងដោយស្របតាមកំណើនប្រជាពលរដ្ឋ និងតម្រូវការនៅលើទីផ្សារជាក់ស្តែង។

កត្តាដំបូងដែលមានសារៈសំខាន់ជាងគេនៅក្នុងទិសដៅនៃការអប់រំ គឺការធានាបាននូវកម្មវិធីសិក្សាមួយមានស្តង់ដារច្បាស់លាស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិត និងសាធារណជនទូទៅក្នុងសង្គម ។ ជាក់ស្តែង សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចបានជ្រើសរើស និងកំណត់នូវកម្មវិធីសិក្សារបស់ខ្លួនស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ជាពិសេស កម្មវិធីសិក្សាត្រូវបានរៀបចំឡើងជាលក្ខណៈប្រព័ន្ធក្រេឌីត ដែលបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) ។ មិនតែប៉ុណ្ណោះ ការសិក្សារបស់និស្សិតគ្រប់វិស័យទាំងអស់ទាំងកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់

និងកម្រិតបណ្ឌិត តម្រូវឲ្យធ្វើការសិក្សាស្រាវជ្រាវជាមូលដ្ឋាន ដើម្បីវាស់វែងនូវចំណុចខ្លាំង និងចំណុចខ្វះខាតរបស់និស្សិតដែលកំពុងតែសិក្សា និងក្រោយពេលបញ្ចប់ការសិក្សារបស់ខ្លួន ។

ដើម្បីសម្រេចទិសដៅខាងលើ សាកលវិទ្យាល័យ បានយកចិត្តទុកដាក់នឹងជម្រុញឲ្យមាន ការអភិវឌ្ឍ និងពង្រឹងគុណភាពលើកត្តាបីជាមូលដ្ឋានគឺៈ ការរៀន ការបង្រៀន និង ការស្រាវជ្រាវដោយផ្តោតលើលទ្ធផលសិក្សារបស់និស្សិត។

ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រង សាកលវិទ្យាល័យមាន ក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង នាយកសាខា ប្រធាន-អនុប្រធានដេប៉ាតឺម៉ង់ ប្រធាន-អនុប្រធានការិយាល័យ និង បុគ្គលិកតាមការិយាល័យ ដែលអនុវត្តតាមបំណែងចែក "**ភារកិច្ច និង ការទទួលខុសត្រូវ**" ។ អមជាមួយនឹងកិច្ចការគ្រប់គ្រង សាកលវិទ្យាល័យ បានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ឆ្លើយតបទៅនឹងបរិបទសង្គមខ្មែរ និង មានលក្ខណៈស្តង់ដារអន្តរជាតិ ដោយមានចំនួនម៉ោងសិក្សាច្រើន ដែលនៅក្នុងនោះមានបញ្ចូលទាំងភាសាអង់គ្លេស សម្រាប់គ្រប់មុខជំនាញទាំងអស់ ក្នុងទិសដៅលើកកម្ពស់សមត្ថភាពនិស្សិត ក៏ដូចជាកិត្យានុភាពរបស់សាកលវិទ្យាល័យ។ ជាងនេះទៅទៀត សាកលវិទ្យាល័យ បានបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ ស្របតាមការវិវត្តន៍របស់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យាព័ត៌មាន ។

ក្រៅពីការងារពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង សាកលវិទ្យាល័យបានធ្វើការជ្រើសរើសសាស្រ្តាចារ្យ ដែលមានសមត្ថភាពខ្ពស់(កម្រិតវប្បធម៌ បទពិសោធន៍ និង និយាមគរុកោសល្យ) ជំនាញឯកទេសច្បាស់លាស់ និងប្រកាន់យកគោលការណ៍ (សច្ចធម៌ យុត្តិធម៌ មនសិការ និង គុណធម៌ )នៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។ ទន្ទឹមនឹងនេះដែរ សាកលវិទ្យាល័យក៏បាននឹងកំពុងជម្រុញលើកទឹកចិត្តឲ្យសាស្រ្តាចារ្យបង្កើននូវការស្រាវជ្រាវលើជំនាញឯកទេសរបស់ខ្លួន នឹងបោះពុម្ពជាសៀវភៅ ដើម្បីផ្តល់នូវភាពងាយស្រួល ក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត ។

ការផ្តល់នូវគុណភាពសិក្សា មិនអាចកាត់ផ្តាច់បានរវាងការបង្រៀនរបស់សាស្រ្តាចារ្យ និង ការរៀនរបស់និស្សិតនោះ សាកលវិទ្យាល័យបានរៀបចំជម្រុញឲ្យនិស្សិតមានវិន័យល្អក្នុងការសិក្សា គោរពគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង ខិតខំប្រឹងប្រែងសិក្សាជាមួយសាស្រ្តាចារ្យ ខិតខំបំពេញកិច្ចការដែលសាស្រ្តាចារ្យផ្តល់ឱ្យ ធ្វើស្វ័យសិក្សា និង ការសិក្សាស្រាវជ្រាវនៅតាមបណ្ណាល័យ ដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំដំណើរជីវិតរបស់ខ្លួនឱ្យក្លាយជា មិត្តល្អរបស់មិត្តភក្រ្ត កូនល្អរបស់ឪពុកម្តាយ និងពលរដ្ឋល្អរបស់សង្គមជាតិ។

## II- សាវតារបស់សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច

សាកលវិទ្យាល័យបានចាប់ផ្តើមបង្កើតតាំងពីឆ្នាំ ១៩៩៨ តាមសេចក្តីប្រកាសលេខ ៩០៨ អយក.ប្រក ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ១៩៩៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានឈ្មោះថាមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញជាន់ខ្ពស់បាត់ដំបង ក្រោយមកបានធ្វើការផ្លាស់ប្តូរទៅជា វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច តាមអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០០ ដោយរាជរដ្ឋាភិបាលកម្ពុជា និងបានប្រែក្លាយទៅជាសាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច តាមអនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦ ដោយរាជរដ្ឋាភិបាលកម្ពុជា។

## III- រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាកលវិទ្យាល័យ

ដើម្បីឱ្យចរន្តការងារបណ្តុះបណ្តាល និងការងារគ្រប់គ្រងសាកលវិទ្យាល័យ ប្រព្រឹត្តទៅបានល្អ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ចបានកំណត់ និង បែងចែកនូវតួនាទី និងភារកិច្ច សម្រាប់ដំណើរការគ្រប់គ្រង ដោយមានភ្ជាប់ជាមួយនឹង តារាងឧបសម្ព័ន្ធ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ ទាំងមូលនៅផ្នែកខាងក្រោយ។

## IV- ទស្សនវិស័យ បេសកកម្ម គោលបំណង និងគុណតម្លៃរបស់សាកលវិទ្យាល័យ

**ទស្សនៈវិស័យ:** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ប្តេជ្ញាបណ្តុះបណ្តាលនិស្សិតឱ្យមានគុណភាព សមត្ថភាព និងក្រមសីលធម៌ នៅក្នុងកម្រិតជាតិ និងអន្តរជាតិ។

**បេសកកម្ម:** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ប្តេជ្ញាបណ្តុះបណ្តាលនិស្សិតឱ្យមាន***គុណភាព និងមានសមត្ថភាពពេញលេញ*** គ្រប់គ្រាន់ក្នុងការស្រូបយកការងារធ្វើ តាមរយៈការរៀន ការបង្រៀន និង***ការស្រាវជ្រាវ*** ដោយ***ផ្តោតលើលទ្ធផលសិក្សាជាអាទិភាព*** របស់និស្សិត។

បេសកកម្មរបស់សាកលវិទ្យាល័យ ពិតជានឹងឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ពីទស្សនៈ និងការងារគ្រប់គ្រងរបស់ថ្នាក់ដឹកនាំសាកលវិទ្យាល័យទាំងបច្ចុប្បន្នកាលក៏ដូចជាអនាគត។ បេសកកម្មជាអាទិភាពចម្បងត្រូវបានកំណត់ នឹងមានចែងដូចតទៅនេះ៖

- បណ្តុះបណ្តាលនិស្សិតឱ្យមានគុណភាព បេសកកម្មនេះជាតម្រូវការដ៏ចាំបាច់បំផុតសម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ពីព្រោះប្រទេសកម្ពុជា ជាប្រទេសមួយមាននីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដោយអាស្រ័យលើរដ្ឋធម្មនុញ្ញ ដែលត្រូវបានគេចាត់ទុកថាជាច្បាប់កំពូល សម្រាប់អនុវត្តន៍នៅទូទាំងប្រទេសលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ពលរដ្ឋកម្ពុជាគ្រប់រូប ដែលបានទទួលការបណ្តុះបណ្តាលប្រកបដោយគុណភាព នោះនឹងក្លាយជាបញ្ញាវន្ត ដែលមានគណនេយ្យភាព និង

អភិបាលកិច្ចល្អ សម្រាប់ប្រទេសជាតិទាំងមូល ជាពិសេសបេសកកម្មនេះនឹងជួយដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនដូចបណ្តាប្រទេសនានាលើសាកលលោក។

- បណ្តុះបណ្តាលនិស្សិតឱ្យមានសមត្ថភាពពេញលេញ គ្រប់គ្រាន់ ជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការកសាងបញ្ញវន្តឲ្យមានសមត្ថភាពគ្រប់គ្រាន់នៅកម្ពុជា។ ដើម្បីឱ្យបេសកកម្មនេះសម្រេចបានទៅតាម ទស្សនៈវិស័យរបស់ខ្លួន វាទាមទារឱ្យនិស្សិតគ្រប់រូបចេះប្រើប្រាស់ចំណេះដឹង ចំណេះធ្វើ និងបំណិនជីវិតប្រកបដោយសុភវិនិច្ឆ័យ នឹង មានតម្លាភាព។
- ការរៀនដោយផ្តោតលើលទ្ធផលសិក្សាជាអាទិភាពរបស់និស្សិត គឺជាមូលដ្ឋានចាំបាច់ក្នុងការទទួលបាននូវគុណភាព និងសមត្ថភាព មានន័យថាការរៀនមិនគ្រាន់តែជាការមកអង្គុយសិក្សាក្នុងថ្នាក់ប៉ុណ្ណោះទេ តែវាជាការដែលនិស្សិតគ្រប់រូបត្រូវខិតខំសិក្សារៀនសូត្រ ត្រង់ត្រាប់ស្តាប់ការពន្យល់ គោរពវិន័យ មានក្រមសីលធម៌ ចូលរួមធ្វើគ្រប់កិច្ចការដែលសាស្ត្រាចារ្យប្រគល់ជូន និងមានខ្ជនៈចូលរួមក្នុងគ្រប់សកម្មភាពនានារបស់សាកលវិទ្យាល័យ និងសង្គមជាតិ ដើម្បីឱ្យទទួលបាននូវពុទ្ធិ ជំនាញ និងចំណេះធ្វើ។
- ការបង្រៀនដោយផ្តោតលើលទ្ធផលសិក្សារបស់និស្សិត គឺជាបេសកកម្មមួយដែលមិនអាចខ្វះបានព្រោះថានិស្សិតមានការចាប់អារម្មណ៍ក្នុងការសិក្សារៀនសូត្របាន លុះត្រាតែសាស្ត្រាចារ្យបានធ្វើការបង្ហាញពីគោលបំណងក្រោយពីការបញ្ចប់នូវមុខវិជ្ជានីមួយៗ មេរៀននីមួយៗ និងចំណុចនីមួយៗ និស្សិតទទួលបានចំណេះដឹងអ្វី ចំណេះធ្វើអ្វី និងឥរិយាបទបែបណា ជាពិសេសបេសកកម្មនេះនឹងជួយជម្រុញឱ្យនិស្សិតកាន់តែមានឆន្ទៈក្នុងការសិក្សាលើមុខវិជ្ជានោះ។
- ការស្រាវជ្រាវដោយផ្តោតលើលទ្ធផលសិក្សារបស់និស្សិត ជាទស្សនទានដ៏ឧត្តុង្គឧត្តម ថ្លៃថ្លាបំផុតនៅលើវិស័យអប់រំសិក្សាធិការក្នុងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ពីព្រោះការកំណត់កិច្ចការសិក្សាស្រាវជ្រាវសម្រាប់និស្សិត ការសិក្សាលើគម្រោងជាអាទិភាព ជាបុព្វហេតុមួយប្រកបដោយទឡ្ហីករណ៍ក្នុងការសម្រេចបាននូវទស្សនៈថ្មីៗ ដើម្បីដោះស្រាយនូវបញ្ហាសង្គម ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន ជាពិសេសបេសកកម្មនេះ ក៏ជាយន្តការមួយដ៏សំខាន់ផងដែរសម្រាប់ជម្រុញទំនាក់ទំនងរវាងនិស្សិត និងសហគមន៍ ដែលនឹងផ្តល់ផលប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

**គោលបំណង:** ដើម្បីសម្រេចនូវបេសកកម្មដ៏ថ្លៃថ្លាខាងលើ សាកលវិទ្យាល័យបានកំណត់នូវគោលបំណងអាទិភាពជាចម្បងៗដូចខាងក្រោម៖

1. អភិបាលកិច្ចលើការងារគ្រប់គ្រង
2. កម្មវិធីសិក្សាផ្តោតលើលទ្ធផលសិក្សារបស់និស្សិត

3. សាស្ត្រាចារ្យបង្រៀនយ៉ាងតិច ៧៥% ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់
4. ជ្រើសរើសនិស្សិតចូលរៀនប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងនិស្សិត
5. គ្រប់គ្រងនិស្សិតមានការងារធ្វើ
6. សម្ភារៈសិក្សា និងសម្ភារៈរូបវន្តគ្រប់គ្រាន់
7. អភិវឌ្ឍការស្រាវជ្រាវ

**គុណតម្លៃ:** គុណតម្លៃរបស់សាកលវិទ្យាល័យមាន៖

- អប់រំ និងបណ្តុះបណ្តាលប្រកបដោយ***គុណភាព*** គុណតម្លៃមួយនេះត្រូវបានមជ្ឈដ្ឋាន ជាច្រើនទទួលស្គាល់ និងឲ្យតម្លៃខ្ពស់ទៅលើគុណភាព និង សមត្ថភាពរបស់និស្សិតទាំងកម្រិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលបានបណ្តុះបណ្តាលដោយសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច នាពេលកន្លងមក។ ជាពិសេស និស្សិតដែលកំពុងបម្រើការងារនៅតាមស្ថាប័នរដ្ឋ និង ឯកជនត្រូវបានអង្គភាពទាំងនោះ លើកសរសើរ និងពេញចិត្តចំពោះសមត្ថភាពរបស់ពួកគេជាខ្លាំង។ គុណតម្លៃខាងលើនេះ គឺសាកលវិទ្យាល័យបានផ្សារភ្ជាប់ជាមួយនឹងធនធានសាស្ត្រាចារ្យ កម្មវិធីសិក្សា សម្ភាររូបវន្ត និងការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ។
- បណ្តុះនិស្សិតឲ្យមានភាព***ក្លាហាន*** ក្នុងការបញ្ចេញមតិចំពោះមហាជននិងសង្គម ភាពក្លាហាន និងការបញ្ចេញមតិ ជាការស្តែងចេញពីសិទ្ធិសេរីភាពរបស់និស្សិតក្នុងការចូលរួមដោយសេរី ដល់ដំណើរការអប់រំយុវជន និងយុវជនដូចគ្នានៅតាមសហគមន៍ក៏ដូចនៅតាមទីសារធារណៈ ដោយមានកម្មវិធីជាច្រើនដូចជា៖ ការអប់រំជំងឺអេដស៍ ការអប់រំអំពីផលប៉ះពាល់នៃគ្រឿងញៀនចំពោះសង្គម ។ ភាពក្លាហាននេះកើតចេញពីសកម្មភាពសិក្សាជាក្រុមរបស់និស្សិតនៅក្នុងថ្នាក់រៀន និងការចូលរួមមតិ ដើម្បីស្វែងរកនូវវិធីសាស្ត្រល្អៗក្នុងការដោះស្រាយបញ្ហា ។
- បណ្តុះនិស្សិតឲ្យមានភាព***មោះមុត*** ចំពោះការងារ ភាពមោះមុតជាតម្លៃស្នូលមួយ ដែលគ្រប់អង្គភាពទាំងអស់លើសាកលលោកប្រាថ្នាចង់បាន ពីព្រោះតម្លៃមួយនេះផ្អែកលើគោលការណ៍បួនយ៉ាង ដែលសាកលវិទ្យាល័យបានធ្វើការបណ្តុះបណ្តាលនិស្សិតនាពេលកន្លងមកគឺ៖ ជម្រុញឲ្យនិស្សិតមានឆន្ទៈក្នុងការងារ យកចិត្តទុកដាក់លើការងារដែលខ្លួនកំពុងធ្វើ មានសេចក្តីព្យាយាមក្នុងការងារ និងត្រិះរិះប្រកបដោយសុភវិនិច្ឆ័យ និងមានតម្លាភាព។
- អប់រំនិស្សិតប្រកបដោយ***ក្រមសីលធម៌*** ខ្ពស់ ក្រមសីលធម៌ ជាសសរស្តម្ភមួយ នៃការអប់រំសម្រាប់មនុស្សជាតិទាំងអស់នៅលើសាកលលោក ពីព្រោះក្រមសីលធម៌អាចកំណត់ឲ្យនិស្សិត បុគ្គលិក សាស្ត្រាចារ្យ និងសាធារណៈជនទាំងអស់ចេះបែងចែកត្រូវខុស សុភាពរាបសារ ចេះឲ្យតម្លៃលើខ្លួនឯង និងអ្នកដទៃ។

- បណ្តុះនូវ***មនសិការជាតិ*** មនសិការជាតិ ជាតម្រូវការដ៏ចាំបាច់នៃការអប់រំនៅក្នុងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ដែលធ្វើឲ្យនិស្សិតគ្រប់រូបចេះស្រឡាញ់ និងថែរក្សាប្រទេសជាតិ អត្តសញ្ញាណជាតិ និងវប្បធម៌ដ៏ថ្លៃថ្លារបស់ខ្លួន ជាពិសេសនិស្សិតបានយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ និងភាពរីកចម្រើនរបស់ប្រទេសជាតិ នាសម័យអតីតកាល ដើម្បីយកមកអភិវឌ្ឍសង្គមឲ្យមានភាពល្ងូតលាស់រីកចម្រើន និងភាពសម្បូរសប្បាយ។

**ការវិភាគ ឱកាស និង ការប្រឈម**

**ក- ឱកាស**

- ស្ថានភាពសង្គមមានស្ថេរភាពផ្នែកនយោបាយ និងសន្តិសុខ
- ស្ថានភាពសេដ្ឋកិច្ចមានការកើនឡើង
- កំណើនទីផ្សារការងារ និងការកើនឡើងនៃការវិនិយោគ
- កំណើនរបស់សិស្សានុសិស្សមានការកើនឡើង
- ឱកាសស្វែងរកការងារធ្វើមានច្រើនទាំងក្នុង និងក្រៅប្រទេស
- មានការទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- មានកិត្តិនាមក្នុងការបណ្តុះបណ្តាលនិស្សិតពីមជ្ឈដ្ឋានខាងក្រៅ

**ខ- ការប្រឈម**

- មានគ្រឹះស្ថានឧត្តមសិក្សាច្រើនក្នុងខេត្តបាត់ដំបង
- គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនយកតម្លៃសិក្សាទាប
- ជីវភាពរស់នៅរបស់ប្រជាជនមានស្ថានភាពមិនអំណោយផលដោយសារវិបត្តិសេដ្ឋកិច្ច
- តម្រូវការនៅលើទីផ្សារការងារនាពេលបច្ចុប្បន្នមិនទាន់ឆ្លើយតបទៅនឹងកម្រិតនៃការបណ្តុះបណ្តាល

# បរិយាយនូវ យុទ្ធសាស្ត្រ និងសកម្មភាព

## ១- គោលបំណងទី១ ៖ អភិបាលកិច្ចលើការងារគ្រប់គ្រង

គឺជាកាតព្វកិច្ចស្នូលក្នុងដំណើរការគ្រប់គ្រងអង្គភាព ឬស្ថាប័នមួយឲ្យមានប្រសិទ្ធភាព និង សម្រេចបាននូវជោគជ័យស្របតាមគម្រោងផែនការសកម្មភាព ដែលបានគ្រោងទុក។ ម៉្យាងវិញទៀត សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចបានកំណត់នូវគោលបំណងនេះឡើងដើម្បីឆ្លើយតបទៅនឹងការងារបណ្តុះបណ្តាលកម្រិតថ្នាក់ឧត្តមសិក្សានៅកម្ពុជា ម្ល៉ោះហើយ ការបង្កើននូវចំណេះដឹង និង ចំណេះធ្វើដល់បុគ្គលិកស្តីការអនុវត្តនូវគោលការណ៍ និងបទបញ្ញត្តិនានា ជាពិសេស ការទទួលខុសត្រូវទៅតាមតួនាទីនិងភារកិច្ចរបស់បុគ្គលិកជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបង្កើត នូវវប្បធម៌គ្រប់គ្រងការងាររួមមួយ មានលក្ខណៈច្បាស់លាស់ត្រឹមត្រូវ នឹងមានប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានចែងថា គណនេយ្យភាព និង អភិបាលកិច្ច ជាផ្នែកមួយ ដែលមិនអាចខ្វះបាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។ សាកលវិទ្យាល័យរំពឹងទុកថាគោលបំណងនេះ នឹងចែករំលែកនូវពុទ្ធិដល់បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិត ឲ្យកាន់តែយល់ច្បាស់ថែមទៀតលើការងារគ្រប់គ្រង និងអភិបាលកិច្ចដើម្បីចូលរួមលើកកំពស់វិជ្ជាជីវៈ ការងាររបស់ខ្លួន និង អភិវឌ្ឍសង្គមជាតិ។ ដើម្បីសម្រេចបានជោគជ័យនូវគោលបំណងខាងលើ សាកលវិទ្យាល័យបានកំណត់នូវយុទ្ធសាស្ត្រចម្បងៗ ជាអាទិភាពដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១៖ ជម្រុញបុគ្គលិកឲ្យយល់ដឹងពីអភិបាលកិច្ចលើការងារគ្រប់គ្រង** ជាយុទ្ធសាស្ត្រស្នូលក្នុងការនាំទៅឱ្យ បុគ្គលិកទាំងអស់យល់ដឹងកាន់តែច្បាស់អំពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំល្អ។ ការជម្រុញឱ្យបុគ្គលិកយល់ដឹងស្តីពីការគ្រប់គ្រង និងអភិបាលកិច្ច ជាទិសដៅមួយដ៏សំខាន់ក្នុងការពង្រឹង សមត្ថភាព និងវិជ្ជាជីវៈការងាររបស់បុគ្គលិកម្នាក់ៗ។ ម៉្យាងវិញទៀត ការបណ្តុះបណ្តាល ស្តីពីការងារគ្រប់គ្រងនិងគណនេយ្យភាពនេះនឹងញ៉ាំងឲ្យបុគ្គលិកចេះប្រើប្រាស់នូវចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ជូនដំណឹងដល់បុគ្គលិកពីការបណ្តុះបណ្តាល អភិបាលកិច្ចល្អ
- សកម្មភាពទី២៖ កំណត់កាលបរិច្ឆេទនៃការបណ្តុះបណ្តាលអភិបាលកិច្ចល្អ
- សកម្មភាពទី៣៖ ជ្រើសរើស និងកំណត់ចំនួនបុគ្គលិកចូលរួមវគ្គបណ្តុះបណ្តាលអភិបាលកិច្ចល្អ
- សកម្មភាពទី៤៖ ផ្តល់វិញ្ញាបនបត្រដល់បុគ្គលិកពេលបញ្ចប់វគ្គសិក្សា

**យុទ្ធសាស្ត្រទី២៖ បែងចែកតួនាទី និងការទទួលខុសត្រូវដល់បុគ្គលិក** ជានីតិវិធីមួយងាយស្រួលក្នុងកំឡុងពេលអនុវត្តនូវកិច្ចការទាំងឡាយ ឲ្យមានលក្ខណៈជាប្រព័ន្ធរដ្ឋបាល និងមានប្រសិទ្ធភាពខ្ពស់។ ពីព្រោះយុទ្ធសាស្ត្រនេះ បង្ហាញកាន់តែច្បាស់អំពីការអនុវត្តនូវការងាររបស់បុគ្គលិកនីមួយៗ ដែលកំពុងតែបម្រើការងារក្នុង

បរិវេណសាកលវិទ្យាល័យ ពិតជានឹងយល់ច្បាស់អំពីកាតព្វកិច្ច ករណីកិច្ច និងតួនាទីរបស់ខ្លួន។ ម៉្យាងវិញទៀត ទិសដៅ មួយនេះ ក៏នឹងអាចកំណត់បានផងដែរ អំពីចំណុចខ្លាំង និងចំណុចខ្វះខាតរបស់បុគ្គលិកម្នាក់ៗនៅពេលដែលប្រតិបត្តិការងារ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចត្រូវកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង
- សកម្មភាពទី២៖ កំណត់តួនាទី និងភារកិច្ចច្បាស់លាស់ដល់បុគ្គលិកម្នាក់ៗ
- សកម្មភាពទី៣៖ ណែនាំឱ្យបុគ្គលិកប្រតិបត្តិតាមតួនាទី និងភារកិច្ចដែលបានចែង
- សកម្មភាពទី៤៖ ផ្សព្វផ្សាយពីរចនាសម្ព័ន្ធ និងការបរិយាយការងារដល់បុគ្គលិក

**យុទ្ធសាស្ត្រទី៣៖ ជម្រុញឱ្យបុគ្គលិកគ្រប់រូបមានការចូលរួម** វប្បធម៌នៃការចូលរួមគឺជាកម្លាំងចលករមួយយ៉ាងធំ ដែលមិនអាចខ្វះបាន នៅក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព មានន័យថាការចូលរួមធ្វើការងារជាក្រុមគឺពិតជាបានជួយជម្រុញឱ្យការងារកាន់តែលឿន និងមានភាពត្រឹមត្រូវ ព្រោះការចូលរួមបានផ្តល់នូវបទពិសោធន៍ថ្មីៗ និងបំណិនការងារដល់បុគ្គលិកគ្រប់គ្នា។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ គ្រប់គ្រង និងសេដ្ឋកិច្ចត្រូវកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ ជម្រុញការងារជាប្រព័ន្ធ
- សកម្មភាពទី២៖ បញ្ជូនបុគ្គលិកចូលរួមក្នុងកម្មវិធីផ្សេងៗ
- សកម្មភាពទី៣៖ ជម្រុញឱ្យបុគ្គលិកគ្រប់រូបមានការសហការ និងមានទំនាក់ទំនងគ្នាបានល្អគ្រប់សកម្មភាព

**យុទ្ធសាស្ត្រទី៤៖ ជម្រុញឱ្យបុគ្គលិកមានតម្លាភាព និងយុត្តិធម៌** យុទ្ធសាស្ត្រនេះពិតជាមានសារសំខាន់ណាស់ដែលជម្រុញឱ្យការងារប្រព្រឹត្តទៅដោយជោគជ័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ គ្រប់គ្រង និងសេដ្ឋកិច្ចត្រូវកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ ជម្រុញឱ្យបុគ្គលិកមានភាពស្មោះត្រង់

**យុទ្ធសាស្ត្រទី៥៖ វាយតម្លៃ និងការលើកទឹកចិត្តបុគ្គលិក** ជាយុទ្ធសាស្ត្រមួយ ដែលឆ្លុះបញ្ចាំង ឲ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្វះខាតលើការប្រតិបត្តិការងាររបស់បុគ្គលិកម្នាក់ និងការលើកទឹកចិត្តចំពោះបុគ្គលិកដែលមានស្នាដៃល្អក្នុងការងារ។ ការវាយតម្លៃនេះ នឹងកំណត់បានច្បាស់ពីតម្រូវការមួយចំនួនដូចជា៖ ការរៀបចំការអនុវត្តការងារ និង ការពិនិត្យវាយតម្លៃផែនការបុគ្គលិកសម្រាប់ពេលបន្ទាប់ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

- សកម្មភាពទី១៖ បង្កើតគណៈកម្មការវាយតម្លៃបុគ្គលិក
- សកម្មភាពទី២៖ រៀបចំទម្រង់បែបបទនៃការវាយតម្លៃ

- សកម្មភាពទី៣៖ កំណត់កាលវិភាគ និងចុះវាយតម្លៃ
- សកម្មភាពទី៤៖ បូកសរុបលទ្ធផល និងធ្វើរបាយការណ៍វាយតម្លៃ
- សកម្មភាពទី៥៖ ផ្តល់អនុសាសន៍ដើម្បីកែលម្អនូវចំណុចខ្វះខាត
- សកម្មភាពទី៦៖ ផ្តល់រង្វាន់ដល់បុគ្គលិកមានស្នាដៃ

**យុទ្ធសាស្ត្រទី៦៖ បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់បុគ្គលិក** ជាយុទ្ធសាស្ត្រស្នូល ដើម្បីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពបុគ្គលិកទាំងអស់ឲ្យយល់ដឹងកាន់តែច្បាស់អំពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំល្អ។ ការរៀបចំវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពបុគ្គលិកស្តីពីការគ្រប់គ្រង ជាទិសដៅមួយដ៏សំខាន់ក្នុងការពង្រឹងសមត្ថភាព និងវិជ្ជាជីវៈការងាររបស់បុគ្គលិកម្នាក់ៗ។ ម្យ៉ាងទៀត ការបណ្តុះបណ្តាល ស្តីការងារគ្រប់គ្រងនិងគណនេយ្យភាពនេះ នឹងញ៉ាំងឲ្យបុគ្គលិកចេះប្រើប្រាស់នូវចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន ក្នុងការបំពេញការងារដោយរលូន។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាលការងារគ្រប់គ្រង ដល់បុគ្គលិក
- សកម្មភាពទី២៖ រៀបចំកម្មវិធីបណ្តុះបណ្តាល
- សកម្មភាពទី៣៖ អញ្ជើញវាគ្មិនមានបទពិសោធន៍លើការងារដឹកនាំ និងគ្រប់គ្រងដើម្បីធ្វើបទបង្ហាញ
- សកម្មភាពទី៤៖ វាយតម្លៃលើលទ្ធផលនៃវគ្គបណ្តុះបណ្តាល
- សកម្មភាពទី៥៖ ចងក្រងឯកសារនៃវគ្គបណ្តុះបណ្តាល

## ២- គោលបំណងទី២ ៖ កម្មវិធីសិក្សាផ្តោតលើលទ្ធផលសិក្សារបស់និស្សិត

កម្មវិធីសិក្សា ជាគោលបំណងមួយយ៉ាងសំខាន់ សម្រាប់ធ្វើការបណ្តុះបណ្តាលបញ្ញាស្មារតីរបស់និស្សិតឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់មូលដ្ឋាន នៃមូលធនបញ្ញារបស់ខ្លួន ស្របតាមបរិបទសេដ្ឋកិច្ចទីផ្សារ និងតម្រូវការជាក់ស្តែងរបស់សង្គម ។ កម្មវិធីសិក្សានៅតាម ភូមិស្ថានសិក្សានីមួយៗ ត្រូវផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែងទៅលើវិស័យជាអាទិភាពមានដូចជា៖ សិល្បៈមនុស្សសាស្ត្រ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា សង្គម និង ភាសាបរទេស ។ ដើម្បីធ្វើឲ្យកម្មវិធីសិក្សាមានលក្ខណៈទាន់សម័យ និង សម្បូរបែប គឺតម្រូវឲ្យ សាស្ត្រាចារ្យបង្ហាញ និងពន្យល់នូវខ្លឹមសារមេរៀន និងអត្ថប្រយោជន៍នៃមេរៀនឲ្យបានច្បាស់លាស់ ដើម្បីបន្ស៊ីចំណេះដឹងរបស់និស្សិតទៅនឹងតម្រូវការទីផ្សារការងារជាក់ស្តែង។ ដូចនេះ កម្មវិធីសិក្សាទាំងកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ត្រូវផ្អែកលើការសិក្សាស្រាវជ្រាវជាមូលដ្ឋាន និង ការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតដែលក្រសួងអប់រំ យុវជន និងកីឡានិង គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃ

កម្ពុជាបានណែនាំ។ ដើម្បីសម្រេចបានជោគជ័យនូវគោលបំណងខាងលើ សាកលវិទ្យាល័យបានកំណត់នូវយុទ្ធសាស្ត្រចម្បងៗ ជាអាទិភាពដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១៖ បង្កើតគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា** ជាយុទ្ធសាស្ត្រមួយដែលឆ្លើយតបទៅនឹងបេសកកម្ម ដែលបានចែងថា៖ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ត្រូវពឹងផ្អែកលើកត្តា កម្មវិធីសិក្សាជាមូលដ្ឋាន។ ដើម្បីឲ្យកម្មវិធីសិក្សាទាំងអស់មានសុពលភាព និងសមស្រប ទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត នោះកម្មវិធីសិក្សាត្រូវបានរៀបចំ ត្រួតពិនិត្យ និងវាយតម្លៃឲ្យបានត្រឹមត្រូវដោយគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាកលវិទ្យាល័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតគោលការណ៍ និងនីតិវិធីនៃការជ្រើសរើស គណៈកម្មការ
- សកម្មភាពទី២៖ អនុវត្តនីតិវិធីជ្រើសរើស និងតែងតាំងសមាសភាពគណៈកម្មការ
- សកម្មភាពទី៣៖ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ
- សកម្មភាពទី៤៖ ផ្សព្វផ្សាយដល់អ្នកដែលពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី២៖ បង្កើតយន្តការតាមដាន ត្រួតពិនិត្យ កែលម្អ និង អភិវឌ្ឍកម្មវិធីសិក្សា** យុទ្ធសាស្ត្រនេះមានសារៈសំខាន់ណាស់ក្នុងការតាមដានការអនុវត្តកម្មវិធីសិក្សាតាមមហាវិទ្យាល័យនីមួយៗ ព្រោះថាការបង្កើតនូវយន្តការមួយនេះគឺក្នុងគោលបំណងស្វែងយល់អំពីចំណុចខ្លាំង ចំណុចខ្វះខាត ដើម្បីងាយស្រួលក្នុងការកែលម្អ និងអភិវឌ្ឍកម្មវិធីសិក្សាឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងសង្គម និងសាកលលោក ជាងនេះទៅទៀតយុទ្ធសាស្ត្រមួយនេះនឹងជួយជម្រុញឱ្យកម្មវិធីសិក្សា របស់សាកលវិទ្យាល័យកាន់តែមានលក្ខណៈប្រសើរឡើងជាលំដាប់។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតសេចក្តីព្រាងយន្តការតាមដាន ត្រួតពិនិត្យ កែលម្អ និងអភិវឌ្ឍកម្មវិធីសិក្សា
- សកម្មភាពទី២៖ ប្រជុំលើកទីមួយលើសេចក្តីព្រាង
- សកម្មភាពទី៣៖ ប្រជុំអនុម័តលើយន្តការតាមដាន ត្រួតពិនិត្យ កែលម្អ និងអភិវឌ្ឍកម្មវិធីសិក្សា
- សកម្មភាពទី៤៖ ផ្សព្វផ្សាយដល់អ្នកដែកពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី៣៖ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងតាមមហាវិទ្យាល័យ** ជាការពិតណាស់កម្មវិធីសិក្សាលើមហាវិទ្យាល័យនីមួយៗ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺចាំបាច់ត្រូវមានធាតុសំខាន់ៗចូលរួមជាច្រើន ក្នុងនោះក៏មានការរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងមហាវិទ្យាល័យនីមួយៗផងដែរ ព្រោះថាការរៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យគឺជាយន្តការស្នូលក្នុងការប្រតិបត្តិលើកម្មវិធីសិក្សា ជាងនេះទៅទៀតការកំណត់នូវរចនាសម្ព័ន្ធ

គ្រប់គ្រងតាមមហាវិទ្យាល័យនីមួយៗបានត្រឹមត្រូវ វានឹងផ្ដល់នូវភាពងាយស្រួលលើការងារគ្រប់គ្រង។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ជ្រើសរើស និងតែងតាំងបុគ្គលិកគ្រប់គ្រង ទៅតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់
- សកម្មភាពទី២៖ កំណត់តួនាទី និងភារកិច្ចបុគ្គលិក
- សកម្មភាពទី៣៖ ប្រជុំផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ច

**យុទ្ធសាស្ត្រទី៤៖ តាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា** ជាយន្តការមួយដ៏សំខាន់ផងដែរ ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យដែលជាក្ដីប្រាថ្នារបស់ថ្នាក់ដឹកនាំសាកលវិទ្យាល័យ ក៏ដូចជាបុគ្គលិកទាំងអស់ ពីព្រោះ ការតាមដាន ត្រួតពិនិត្យវាយតម្លៃការអនុវត្តកម្មវិធីសិក្សា ជាមូលដ្ឋានមួយដែលមិនអាចខ្វះបានសម្រាប់ធ្វើការ បណ្ដុះបណ្ដាលធនធានមនុស្ស ប្រកបដោយចីរភាព។ ជាពិសេស កម្មវិធីសិក្សាដែលផ្អែកលើវិស័យទាំងបួនដូចជា វិស័យសិល្បៈ និង មនុស្សសាស្ត្រ វិស័យវិទ្យាសាស្ត្រសង្គម វិស័យវិទ្យាសាស្ត្រពិត និង វិទ្យាសាស្ត្រកុំព្យូទ័រ និង វិស័យភាសាបរទេសជាដើម មានអត្ថប្រយោជន៍ យ៉ាងច្រើនក្នុងបរិបទអភិវឌ្ឍន៍ប្រទេសជាតិ ដែលស្របតាមនិន្នាការនៃសាកលលោកភាវូបនីយកម្ម នាពេលបច្ចុប្បន្ន។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ រៀបចំគម្រោងមេរៀន
- សកម្មភាពទី២៖ ជម្រុញឱ្យសាស្ត្រាចារ្យរៀបចំកិច្ចតែងការបង្រៀន
- សកម្មភាពទី៣៖ ជម្រុញការចុះសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យ
- សកម្មភាពទី៤៖ ធ្វើសម្រង់មតិរបស់និស្សិតចំពោះសាស្ត្រាចារ្យ និងមុខវិជ្ជា

**យុទ្ធសាស្ត្រទី៥៖ អភិវឌ្ឍកម្មវិធីសិក្សា ផ្ដោតលើលទ្ធផលសិក្សារបស់និស្សិត** យុទ្ធសាស្ត្រមួយនេះមិនអាចខ្វះបានទេក្នុងបរិបទទីផ្សារសេរី ព្រោះថាការផ្ដល់នូវលទ្ធផលសិក្សាដល់និស្សិតប្រកបដោយគុណភាព និងសមត្ថភាពនោះ គឺទាមទារឱ្យសាកលវិទ្យាល័យខិតខំអភិវឌ្ឍកម្មវិធីសិក្សារបស់ខ្លួនជាប្រចាំ ដែលក្នុងនោះរួមមានការវាយតម្លៃការសិក្សារបស់និស្សិតប្រចាំ ជម្រុញកិច្ចការស្រាវជ្រាវដល់និស្សិត បង្កើនប្រសិទ្ធភាពលើលទ្ធផលសិក្សារបស់និស្សិត បង្កើនចំណេះដឹង ចំណេះធ្វើ និងឥរិយាបទល្អសម្រាប់និស្សិតនៅពេលបញ្ចប់ចំណាងជើងនីមួយៗ មេរៀននីមួយៗ និងមុខវិជ្ជាទាំងមូល។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ សិក្សាស្រាវជ្រាវពីតម្រូវការលើកម្មវិធីសិក្សារបស់មជ្ឈដ្ឋានខាងក្រៅ
- សកម្មភាពទី២៖ សិក្សាស្រាវជ្រាវពីតម្រូវការរបស់និស្សិតគ្រប់មហាវិទ្យាល័យលើកម្មវិធីសិក្សា
- សកម្មភាពទី៣៖ ជម្រុញឲ្យមានការចូលរួមចងក្រង និងអភិវឌ្ឍកម្មវិធីសិក្សាពីបុគ្គលិក

- សកម្មភាពទី៤៖ ជម្រុញឲ្យមានការចូលរួមចងក្រង និងអភិវឌ្ឍកម្មវិធីសិក្សាពីសាស្ត្រាចារ្យ
- សកម្មភាពទី៥៖ ប្រជុំសម្រេចលើការអភិវឌ្ឍកម្មវិធីសិក្សា
- សកម្មភាពទី៦៖ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី៦៖ ផ្សព្វផ្សាយកម្មវិធីសិក្សា** យុទ្ធសាស្ត្រនៃការផ្សព្វផ្សាយគឺមិនអាចខ្វះបានទេក្នុងការអប់រំបណ្ដុះ បណ្ដាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។ ការផ្សព្វផ្សាយកម្មវិធីសិក្សាដល់បុគ្គលិក សាស្ត្រាចារ្យ និស្សិត និងអ្នកពាក់ព័ន្ធ គឺជាការបង្ហាញនូវអ្វីដែលសាកលវិទ្យាល័យមាន និងកំពុងអនុវត្តនូវកម្មវិធីសិក្សាមួយដែលមានភាពច្បាស់លាស់ និងត្រឹមត្រូវតាមបទដ្ឋានជាតិ និងមានលក្ខណៈអន្តរជាតិ ដើម្បីឱ្យអ្នកទាំងអស់នោះបានដឹង ក៏ដូចជាការទាញការចាប់អារម្មណ៍របស់ពួកគេផងដែរ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ប្រជុំ ឫសិក្ខាសាលា
- សកម្មភាពទី២៖ គេហទំព័ររបស់សាកលវិទ្យាល័យ, វិទ្យុ, ព្រឹត្តប័ត្រ, Leaflet, បដា...
- សកម្មភាពទី៣៖ ចុះតាមវិទ្យាល័យនានាក្នុងខេត្ត

## ៣- គោលបំណងទី៣៖ សាស្ត្រាចារ្យបង្រៀនយ៉ាងតិច ៧៥% ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់

សាស្ត្រាចារ្យ គឺជាកម្លាំងចលករមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសាកលវិទ្យាល័យឱ្យមានការរីកចម្រើនជឿនលឿន ដូចនេះដើម្បីឱ្យបុគ្គលិកសិក្សាទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្ទេរចំណេះដឹងដល់និស្សិត និងនិស្សិតអាចទទួលយកបានលើវិស័យឧត្តមសិក្សា សាកលវិទ្យាល័យមានយន្តការអភិវឌ្ឍសមត្ថភាព និងចំណេះដឹងដល់សាស្ត្រាចារ្យជាប្រចាំ ដើម្បីបង្កើនសមត្ថភាពក្នុងការផ្ទេរចំណេះដឹងដល់និស្សិត។ ដូចនេះ ក្នុងយុទ្ធសាស្ត្រនេះ សាកលវិទ្យាល័យចាំបាច់ត្រូវបង្កើននូវចំនួនសាស្ត្រាចារ្យដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឱ្យបានច្រើន តាមរយៈការជ្រើសរើស និងការអនុញ្ញាតឱ្យបន្តការសិក្សាដោយបញ្ចុះតម្លៃសិក្សាពិសេស។ ដើម្បីសម្រេចបានជោគជ័យនូវគោលបំណងខាងលើ សាកលវិទ្យាល័យបានកំណត់នូវយុទ្ធសាស្ត្រចម្បងៗជាអាទិភាពដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១៖ បង្កើតគណៈកម្មការជ្រើសរើសសាស្ត្រាចារ្យ** ជាយុទ្ធសាស្ត្រមួយដែលឆ្លើយតបទៅនឹងបេសកកម្ម ដែលបានចែងថា៖ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ត្រូវពឹងផ្អែកលើកត្តា សាស្ត្រាចារ្យជាមូលដ្ឋាន។ ដើម្បីឱ្យសាស្ត្រាចារ្យគ្រប់រូបមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀន នូវខ្លឹមសារដែលស្របទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត នោះសាស្ត្រាចារ្យម្នាក់ៗត្រូវបានជ្រើសរើស ត្រួតពិនិត្យ និងវាយតម្លៃយ៉ាងត្រឹមត្រូវដោយគណៈកម្មការជ្រើសរើសរបស់សាកលវិទ្យាល័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតគោលការណ៍ និងនីតិវិធីនៃការជ្រើសរើស គណៈកម្មការ

- សកម្មភាពទី២៖ អនុវត្តនីតិវិធីជ្រើសរើស និងតែងតាំងសមាសភាពគណៈកម្មការ
- សកម្មភាពទី៣៖ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ
- សកម្មភាពទី៤៖ ផ្សព្វផ្សាយដល់អ្នកដែកពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី២៖ ធ្វើការជ្រើសរើសសាស្ត្រាចារ្យ** ដំណើរការនៃការជ្រើសរើសសាស្ត្រាចារ្យគឺជាដំណាក់មួយដែលសាកលវិទ្យាល័យបានអនុវត្តជាប្រចាំ ដើម្បីទទួលបានសាស្ត្រាចារ្យដែលមានបទពិសោធន៍ល្អ ក្នុងការផ្ទេរចំណេះដឹងដល់និស្សិត។ ជាទូទៅការជ្រើសសាស្ត្រាចារ្យ គឺត្រូវបានយកចិត្តទុកដាក់ជាចម្បងដោយថ្នាក់ដឹកនាំសាកលវិទ្យាល័យ តាមរយៈការបង្កើតគណៈកម្មការ ការពិនិត្យនូវពាក្យស្នើសុំ សញ្ញាបត្រ បទពិសោធន៍ក្នុងការបង្រៀន និងការសម្ភាសន៍។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ចេញសេចក្តីជូនដំណឹងជាសាធារណៈ
- សកម្មភាពទី២៖ ពិនិត្យ CV សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងឯកសារពាក់ព័ន្ធ
- សកម្មភាពទី៣៖ ធ្វើតេស្ត ឬធ្វើការសំភាសន៍
- សកម្មភាពទី៤៖ ចេញសេចក្តីសម្រេចជ្រើសរើស
- សកម្មភាពទី៥៖ ប្រជុំណែនាំពីការងារ និងបទបញ្ជារបស់សាកលវិទ្យាល័យ

**យុទ្ធសាស្ត្រទី៣៖ ការផ្ទេរចំណេះដឹង និងការគ្រប់គ្រងថ្នាក់រៀន** យុទ្ធសាស្ត្រទី៣នេះពិតជាមិនអាចខ្វះបានទេក្នុងយន្តការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព។ ការផ្ទេរចំណេះដឹងដល់និស្សិតគឺជាការខិតខំរៀបចំកិច្ចតែងការបង្រៀន ការប្រើវិធីសាស្ត្របង្រៀនដែលល្អ និងការបង្ហាញពីលទ្ធផលរំពឹងទុក ដោយផ្តោតលើលទ្ធផលសិក្សារបស់និស្សិត។ ការគ្រប់គ្រងថ្នាក់រៀនគឺជាលក្ខខណ្ឌចាំបាច់មួយដែលគ្រប់សាស្ត្រាចារ្យទាំងអស់ត្រូវធ្វើ ដើម្បីទាញការចាប់អារម្មណ៍របស់និស្សិតនៅក្នុងខ្លឹមសារនៃមុខវិជ្ជានីមួយៗ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ រៀបចំសាស្ត្រាចារ្យដែលមានចំណេះដឹងបរិញ្ញាបត្រជាន់ខ្ពស់ ឬបរិញ្ញាបត្រដែលមាន បទពិសោធន៍យ៉ាងតិច ៣ឆ្នាំ
- សកម្មភាពទី២៖ រៀបចំសាស្ត្រាចារ្យឱ្យបង្រៀនស្របតាមជំនាញ និងបទពិសោធន៍របស់គាត់
- សកម្មភាពទី៣៖ ជម្រុញសាស្ត្រាចារ្យបង្ហាញពីវិធីសាស្ត្របង្រៀន គោលបំណងមេរៀន ការវាយតម្លៃការសិក្សា និងលទ្ធផលរំពឹងទុកដល់និស្សិត
- សកម្មភាពទី៤៖ ជម្រុញការគ្រប់គ្រងវិន័យ និងអប់រំសុជីវធម៌ សីលធម៌រស់នៅជាប្រចាំ
- សកម្មភាពទី៥៖ ជម្រុញសាស្ត្រាចារ្យដាក់កិច្ចការជាក្រុម និងកិច្ចការផ្ទះដល់និស្សិត

- សកម្មភាពទី៦៖ ជម្រុញសាស្ត្រាចារ្យឱ្យមានការលើកទឹកចិត្តដល់និស្សិត
- សកម្មភាពទី៧៖ ណែនាំសាស្ត្រាចារ្យឱ្យគោរពពេលវេលា និងមានទំនាក់ទំនងល្អជាមួយនិស្សិត
- សកម្មភាពទី៨៖ ការប្រជុំបច្ចេកទេសដើម្បីដោះដូរបទពិសោធន៍បង្រៀន

**យុទ្ធសាស្ត្រទី៤៖ បណ្តុះបណ្តាលចំណេះដឹង និងសមត្ថភាពបន្ថែម** ជាយុទ្ធសាស្ត្រមួយ ដែលនឹងនាំឲ្យសាកលវិទ្យាល័យទទួលបាននូវធនធានសាស្ត្រាចារ្យដែលមានចំណេះដឹង និងសមត្ថភាពខ្ពស់ក្នុងការបង្រៀននិស្សិត។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រនេះ ជម្រុញឲ្យសាស្ត្រាចារ្យគ្រប់រូបទាំងអស់បាន អភិវឌ្ឍនូវចំណេះដឹងរបស់ខ្លួន ឲ្យស្របទៅតាមការរីកចម្រើនខាងវិទ្យាសាស្ត្របច្ចេកវិទ្យារបស់សង្គម។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

- សកម្មភាពទី១៖ រៀបចំកម្មវិធីបណ្តុះបណ្តាល
- សកម្មភាពទី២៖ បើកវគ្គខ្លី ដើម្បីបំប៉នលើជំនាញឯកទេស
- សកម្មភាពទី៣៖ បញ្ជូនឱ្យចូលរួមក្នុងវគ្គសិក្ខាសាលា (ខាងក្នុង ឫខាងក្រៅ)
- សកម្មភាពទី៤៖ បញ្ជូនឱ្យចូលរួមក្នុងដំណើរទស្សនៈកិច្ច (ខាងក្នុង ឫខាងក្រៅ)

**យុទ្ធសាស្ត្រទី៥៖ វាយតម្លៃការបង្រៀន** ជាយុទ្ធសាស្ត្រមួយដែលនឹងនាំឲ្យ សាកលវិទ្យាល័យកំណត់បាននូវសមត្ថភាពបង្រៀនពិតៗរបស់សាស្ត្រាចារ្យម្នាក់ៗ។ ជាពិសេសជាងនេះទៅទៀតនោះ ការវាយតម្លៃនេះក៏នឹងបង្ហាញផងដែរ នូវការយកចិត្តទុកដាក់បង្រៀន និង ការងារអប់រំបណ្តុះបណ្តាលរបស់ពួកគាត់ម្នាក់ៗ ព្រោះថាការ វាយតម្លៃការបង្រៀនល្អគឺជាមូលដ្ឋាននៃការលើកទឹកចិត្ត។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ វាយតម្លៃដោយគណៈកម្មការ
- សកម្មភាពទី២៖ វាយតម្លៃតាមសម្រង់មតិរបស់និស្សិត
- សកម្មភាពទី៣៖ ផ្តល់លទ្ធផលនៃការវាយតម្លៃដល់សាស្ត្រាចារ្យ ដើម្បីឱ្យសាស្ត្រាចារ្យធ្វើការកែលម្អ

***យុទ្ធសាស្ត្រទី៦៖ ការលើកទឹកចិត្តសាស្ត្រាចារ្យ*** ជាយុទ្ធសាស្ត្រមួយដែលនឹងធ្វើឲ្យសាស្ត្រាចារ្យមានភាពស្និទ្ធស្នាលជាមួយនឹង បុគ្គលិក អ្នកគ្រប់គ្រង និងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការងារបង្រៀនរបស់ខ្លួនដែលកំពុងតែប្រតិបត្តិ។ ម៉្យាងវិញទៀត ការលើកទឹកចិត្តគឺជាការជម្រុញឱ្យសាស្ត្រាចារ្យគ្រប់រូបកាន់តែមានឆន្ទៈក្នុងការបំពេញការងារកាន់តែប្រសើឡើងៗ ជាពិសេសយុទ្ធសាស្ត្រនេះនឹងនាំឲ្យសាកលវិទ្យាល័យជ្រើសរើសបាននូវសាស្ត្រាចារ្យ ដែលមានចំណេះដឹងបទពិសោធន៍ និងមនសិការវិជ្ជាជីវៈខ្ពស់។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះ សម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ ប្រគល់ជូនបណ្ណសរសើរ
- សកម្មភាពទី២៖ តំឡើងឋានៈ និងបង្កើនអត្រាប្រាក់ម៉ោងបង្រៀន
- សកម្មភាពទី៣៖ បង្កើនចំនួនថ្នាក់បង្រៀន

- សកម្មភាពទី៤៖ ផ្ដល់ការបញ្ចុះតម្លៃពិសេសលើការសិក្សាបន្តនៅ UME
- សកម្មភាពទី៥៖ ផ្ដល់នូវដំណើរកំសាន្តផ្សេងៗ

**យុទ្ធសាស្ត្រទី៧៖ ជម្រុញការទំនាក់ទំនងជាមួយសាកលវិទ្យាល័យដៃគូរលើធនធានសាស្ត្រាចារ្យ** ជាយុទ្ធសាស្ត្រមួយដែលនឹងធ្វើឲ្យសាកលវិទ្យាល័យកាន់តែមានភាពល្បីល្បាញ ដោយសារមានសាស្ត្រាចារ្យបរទេសមកបង្រៀន ដែលបានផ្ដល់បទពិសោធន៍ថ្មី ចំណេះដឹងថ្មីដល់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះ សម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ ចុះអនុសរណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យផ្សេងៗ
- សកម្មភាពទី២៖ ធ្វើការផ្លាស់ប្ដូរសាស្ត្រាចារ្យបង្រៀន
- សកម្មភាពទី៣៖ ធ្វើការទំនាក់ទំនងជាប្រចាំ

## ៤- គោលបំណងទី៤៖ ជ្រើសរើសនិស្សិតចូលសិក្សាប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងនិស្សិត

យុទ្ធសាស្ត្រនេះ គឺជាតម្លៃស្នូលមួយដែលគណៈគ្រប់គ្រងសាកលវិទ្យាល័យកំពុងនឹងបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់ ពីព្រោះភាពជោគជ័យដែលសាកលវិទ្យាល័យទទួលបានរហូតមកដល់ពេលនេះក៏អាស្រ័យនឹងការផ្ដោតយកចិត្តទុកដាក់លើគុណភាពសិក្សារបស់និស្សិតជាចម្បង។ គុណភាពសិក្សាមានន័យថា ការផ្ដល់នូវចំណេះដឹង និងវិជ្ជាជីវៈដល់និស្សិតផ្អែកលើគោលការណ៍គ្រឹះបីយ៉ាងសំខាន់គឺ ពុទ្ធិ បំនិន និងក្រមសីលធម៌។ដោយឡែកការជ្រើសរើស និងការគ្រប់គ្រងនិស្សិតក៏រិតតែសំខាន់ទៅទៀតដោយហេតុថាដើម្បីទទួលបាននូវគុណភាពចាំបាច់ត្រូវការមានការជ្រើសរើសនិស្សិត ដែលបំពេញគ្រប់លក្ខខណ្ឌមកទទួលការបណ្ដុះបណ្ដាលពីសាស្ត្រាចារ្យមានបទពិសោធន៍ បូករួមជាមួយការគ្រប់គ្រងវិន័យ ការគ្រប់គ្រងវត្តមានបានត្រឹមត្រូវច្បាស់លាស់។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាកលវិទ្យាល័យ បានរៀបចំនូវយុទ្ធសាស្ត្រ និង សកម្មភាពជាច្រើនដើម្បីអនុវត្តដូចខាងក្រោមនេះ៖

**យុទ្ធសាស្ត្រទី១៖ បង្កើតគណៈកម្មការជ្រើសរើសនិស្សិត** ជាយុទ្ធសាស្ត្រមួយដែលឆ្លើយតបទៅនឹងបេសកកម្ម ដែលបានចែងថា៖ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ត្រូវពឹងផ្អែកលើមូលដ្ឋាន នៃចំណេះដឹងរបស់ពួកគាត់ពីមធ្យមសិក្សាទុតិយភូមិមក។ ដើម្បីឱ្យនិស្សិតគ្រប់រូបមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រ នូវខ្លឹមសារដែលសាស្ត្រាចារ្យបានបង្រៀននោះ និស្សិតម្នាក់ៗត្រូវបានជ្រើសរើស និងវាយតម្លៃយ៉ាងត្រឹមត្រូវដោយគណៈកម្មការជ្រើសរើសរបស់សាកលវិទ្យាល័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ចេញសេចក្ដីសម្រេចបង្កើតគណៈកម្មការ
- សកម្មភាពទី២៖ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ
- សកម្មភាពទី៣៖ ផ្សព្វផ្សាយដល់អ្នកដែកពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី២៖ ធានាបាននូវការជ្រើសរើសនិស្សិតប្រកបដោយប្រសិទ្ធភាព** យុទ្ធសាស្ត្រនេះនេះ គឺជាតម្លៃស្នូលមួយដែលមិនអាចខ្វះបាន ពីព្រោះភាពជោគជ័យដែលសាកលវិទ្យាល័យទទួលបានរហូតមកដល់ពេលនេះក៏អាស្រ័យនឹងការផ្តោតយកចិត្តទុកដាក់លើគុណភាពសិក្សារបស់និស្សិតជាចម្បង។ គុណភាពសិក្សាតែងតែផ្សារភ្ជាប់ទៅនឹងការជ្រើសរើសនិស្សិតចូលរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាក់ស្តែងប្រសិនបើសាកលវិទ្យាល័យជ្រើសរើសបាននិស្សិតដែលបំពេញគ្រប់លក្ខខណ្ឌចូលមកសិក្សា នោះជាកត្តាមួយដែលបង្កភាពងាយស្រួលដល់ការបង្រៀនរបស់សាស្ត្រាចារ្យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតគោលការណ៍ និងនីតិវិធី

  -ស្តីពីការជ្រើសរើសនិស្សិតចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

  -ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍

  -ស្តីពីផ្ទេរការសិក្សា និងការទទួលនិស្សិតផ្ទេរចូល

- សកម្មភាពទី២៖ ធ្វើការជ្រើសរើសដោយផ្អែកតាមព្រឹត្តិបត្តិពិន្ទុប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ

  ចំពោះបេក្ខជនប្រឡងជាប់ចាប់ពីឆ្នាំ ២០០២ មកដល់បច្ចុប្បន្ន

  -ធ្វើការពិនិត្យ និងកំណត់យកពិន្ទុតាមមុខវិជ្ជាយ៉ាងទាបត្រឹមនិទ្ទេស E និងឱ្យស្របតាមជំនាញដែលបេក្ខជនជ្រើសរើស

  -រៀបចំបញ្ជីឈ្មោះនិស្សិតដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ

- សកម្មភាពទី៣៖ ធ្វើការប្រឡងចូលសម្រាប់បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុន ឆ្នាំ២០០២

  -ធ្វើសំណើរស្នើសុំប្រឡងចូលរៀនទៅក្រសួងអប់រំយុវជន និងកីឡា

  -រៀបចំវិញ្ញាសាប្រឡងតាមជំនាញដែលបេក្ខជនជ្រើសរើស

  -រៀបចំបញ្ជីឈ្មោះបេក្ខជនតាមបន្ទប់

  -ប្រជុំបែងចែកភារកិច្ចគណៈមេប្រយោគ

  -គ្រប់គ្រងដំណើរការប្រឡង

  -ធ្វើកំណែសន្លឹកកិច្ចការបេក្ខជន

  -ចេញលទ្ធផលនៃការប្រឡងជ្រើសរើស

  -រៀបចំបញ្ជីឈ្មោះសុំការទទួលស្គាល់ពីក្រសួងអប់រំយុវជន និងកីឡា

- សកម្មភាពទី៤៖ ចំពោះបេក្ខជនដាក់ពាក្យចូលសិក្សាមហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងភាសាបរទេស ជំនាញភាសាអង់គ្លេស ត្រូវប្រឡងចូលទាំងអស់លើវិញ្ញាសាតាមការកំណត់របស់ក្រសួងអប់រំយុវជន និង កីឡា

- សកម្មភាពទី៥៖ ផ្តល់អាហារូបករណ៍ដល់និស្សិតពូកែ និងនិស្សិតអាទិភាព

**យុទ្ធសាស្ត្រទី៣៖ ការគ្រប់គ្រងស្ថិតិនិស្សិត** ជាយុទ្ធសាស្ត្រមួយ ដែលនឹងអាចធ្វើឲ្យសាកលវិទ្យាល័យមានការ ងាយស្រួលក្នុងការតាមដាននូវចំនួននិស្សិតដែលនឹងកំពុងសិក្សាជាក់ស្តែង ម៉្យាងវិញទៀតវាក៏ជួយតាមដានសកម្មភាពសិក្សារបស់និស្សិតគ្រប់កម្រិតសិក្សាទាំងអស់ឲ្យកាន់តែចូលរួមយ៉ាងសកម្ម និងខិតខំប្រឹងប្រែងសិក្សារៀនសូត្រដើម្បីអនាគតរបស់ពួកគេ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ចាត់តាំងបុគ្គលិកទទួលខុសត្រូវ
- សកម្មភាពទី២៖ តាមដាននិស្សិតកំពុងរៀន និស្សិតបោះបង់ និស្សិតព្យួរការសិក្សា និស្សិតផ្ទេរចូល
- សកម្មភាពទី៣៖ យកចិត្តទុកដាក់ចំពោះនិស្សិតទាំងអស់

**យុទ្ធសាស្ត្រទី៤៖ ការគ្រប់គ្រងវិន័យនិស្សិត** ជាយុទ្ធសាស្ត្រមួយដែលអាចកំណត់បានពីភារកិច្ច និងការទទួលខុសត្រូវ ចំពោះការគ្រប់គ្រងលើកិច្ចបង្រៀននិងសិក្សារបស់និស្សិត ដើម្បីធានានូវការសិក្សាអប់រំមួយប្រកប ដោយគុណភាពនិងជួយឲ្យនិស្សិតទទួលបាននូវការអប់រំចរិយាធម៌ ក្នុងការធ្វើខ្លួនរបស់និស្សិតឲ្យក្លាយទៅជានិស្សិតល្អ កូនល្អ និងពលរដ្ឋនៅក្នុងសង្គមកម្ពុជា។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិត
- សកម្មភាពទី២៖ បង្កើតគណៈកម្មការវិន័យ
- សកម្មភាពទី៣៖ អនុវត្តតាមគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនិស្សិត
- សកម្មភាពទី៤៖ ណែនាំនិស្សិតមិនគោរពវិន័យ

**យុទ្ធសាស្ត្រទី៥៖ ការគ្រប់គ្រងសកម្មភាពសិក្សា** ជាយុទ្ធសាស្ត្រមួយ ដែលនឹងអាចធ្វើឲ្យសាកលវិទ្យាល័យងាយស្រួលតាមដាននូវសកម្មភាពសិក្សារបស់និស្សិតគ្រប់កម្រិតសិក្សាទាំងអស់ឲ្យរឹងរឹត កាន់តែចូលរួមយ៉ាងសកម្មនឹងខិតខំប្រឹងប្រែងសិក្សារៀនសូត្រ។ម៉្យាងទៀតយុទ្ធសាស្ត្រនេះនឹងជួយផ្តល់នូវសេវាកម្មនានាការផ្តល់យោបល់ ចំពោះការសិក្សារបស់ពួកគេ បន្ថែមលើនោះធ្វើឱ្យនិស្សិតកាន់តែទទួលបាននូវចំណេះដឹងសមស្របបន្ថែមទៀត ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ កំណត់ចំនួននិស្សិតសមរម្យក្នុងថ្នាក់នីមួយៗ
- សកម្មភាពទី២៖ តាមដានការសិក្សា និងអវត្តមានរបស់និស្សិត

- សកម្មភាពទី៣៖ ពង្រីកកិច្ចការនិស្សិត និងការចុះកម្មសិក្សា
- សកម្មភាពទី៤៖ បណ្តុះបណ្តាលបន្ថែមនិស្សិតខ្សោយ និងឫជម្រុញឱ្យមានស្វ័យសិក្សាតាមក្រុម
- សកម្មភាពទី៥៖ វាយតម្លៃការសិក្សាដោយផ្តោតលើលទ្ធផលសិក្សា និងពង្រឹងកិច្ចការប្រឡង
- សកម្មភាពទី៦៖ ផ្តល់ការពិគ្រោះយោបល់ដល់និស្សិតក្នុងគ្រប់សកម្មភាព (ការសិក្សា ការជ្រើសជំនាញ)
- សកម្មភាពទី៧៖ ផ្តល់ពត៌មានទូទៅ និងសេវាផ្សេងៗសម្រាប់និស្សិតទូទៅ

**យុទ្ធសាស្រ្តទី៦៖ កម្មវិធីបណ្តុះបណ្តាលបន្ថែម** ជាយុទ្ធសាស្ត្រមួយ ដែលនឹងអាចធ្វើឲ្យនិស្សិតកាន់តែទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ក្រៅពីការសិក្សាទ្រឹស្តី។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ រៀបចំកម្មវិធីសិក្ខាសាលា
- សកម្មភាពទី២៖ រៀបចំកម្មវិធីទស្សនៈកិច្ចសិក្សា
- សកម្មភាពទី៣៖ អញ្ជើញអ្នកមានបទពិសោធន៍មកធ្វើបទបង្ហាញផ្ទាល់ដល់និស្សិត
- សកម្មភាពទី៤៖ រៀបចំកម្មវិធីចំណេះដឹងទូទៅ
- សកម្មភាពទី៥៖ បង្កើតក្លឹបរៀនភាសាអង់គ្លេស
- សកម្មភាពទី៦៖ បង្កើតវគ្គសិក្សាខ្លីៗ
- សកម្មភាពទី៧៖ ធ្វើការដោះដូរការសិក្សារបស់និស្សិតជាមួយដៃគូរបរទេស

**យុទ្ធសាស្ត្រទី៧៖ ការលើកទឹកចិត្តដល់និស្សិតឆ្នើម** ជាយុទ្ធសាស្ត្រមួយ ដែលមិនអាចខ្វះបាននៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ព្រោះថាការលើកទឹកចិត្តគឺជាកត្តាមួយដែលជួយជម្រុញឱ្យនិស្សិតគ្រប់រូបកាន់តែមានឆន្ទៈក្នុងការប្រកួតប្រជែងដើម្បីទទួលបាននូវជោគជ័យ និងមានការលើកទឹកចិត្តពីសាកលវិទ្យាល័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ផ្តល់ជាប័ណ្ណសរសើរ
- សកម្មភាពទី២៖ ផ្តល់ដំណើរកំសាន្តផ្សេងៗ
- សកម្មភាពទី៣៖ ជួយរកកន្លែងចុះកម្មសិក្សាស្ម័គ្រចិត្ត
- សកម្មភាពទី៤៖ ផ្តល់អាទិភាពក្នុងការសិក្សានៅបរទេស

**៥- គោលបំណងទី៥៖ គ្រប់គ្រងនិស្សិតមានការងារធ្វើ** គោលបំណងនេះគឺជាសេចក្តីប្រាថ្នាដ៏ចម្បងជាងគេបង្អស់សម្រាប់និស្សិតដែលកំពុងតែសិក្សានិង និស្សិតដែលនឹងត្រូវបញ្ចប់ការសិក្សា ពីព្រោះនៅពេលដែលនិស្សិតមានការងារធ្វើកាន់តែច្រើននាក់ នោះមានន័យថា និស្សិតពិតជាបាន កែប្រែជីវភាពរស់នៅរបស់ខ្លួន នឹង

កំពុងតែជួយអភិវឌ្ឍប្រទេសជាតិ។ ដើម្បីធានាបាននូវសមភាពការងារនិងទំហំការងារកើនឡើង ចំណុចដែលសាកលវិទ្យាល័យបានយកចិត្តទុកដាក់ខ្លាំងជាងគេគឺការទំនាក់ទំនងរវាងសាកលវិទ្យាល័យជាមួយនឹងអង្គការ ឬក៏ក្រុមហ៊ុននានា ឲ្យឃើញកាន់តែច្បាស់អំពីគុណភាពសិក្សា និង សមត្ថភាពការងាររបស់និស្សិត។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាកលវិទ្យាល័យ បានរៀបចំនូវយុទ្ធសាស្ត្រ និង សកម្មភាពជាច្រើនដើម្បីអនុវត្តដូចខាងក្រោមនេះ៖

**យុទ្ធសាស្ត្រទី១៖ បង្កើតគណៈកម្មការពិគ្រោះយោបល់ក្នុងការស្វែងរកការងារជូននិស្សិត** ជាយុទ្ធសាស្ត្រមួយដែលមិនអាចខ្វះបានក្នុងកិច្ចការស្វែងរកការងារជូននិស្សិត។ យុទ្ធសាស្ត្រមួយនេះនឹងកំណត់បាន នូវគោលការណ៍មួយជាក់លាក់ និងមានសុក្រឹតភាពក្នុងការធានាឲ្យមានការងារសម្រាប់និស្សិត។ ជាពិសេសគណៈកម្មការនេះ ចាំបាច់ត្រូវតែមានយុត្តិធម៌អព្យាក្រឹតនិងតម្លាភាព ក្នុងការពិគ្រោះយោបល់ដល់និស្សិតទូទៅ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាកលវិទ្យាល័យ បានរៀបចំនូវយុទ្ធសាស្ត្រ និង សកម្មភាពជាច្រើនដើម្បីអនុវត្តដូចខាងក្រោមនេះ៖

- សកម្មភាពទី១៖ ចេញសេចក្តីសម្រេចបង្កើតគណៈកម្មការ
- សកម្មភាពទី២៖ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ
- សកម្មភាពទី៣៖ ផ្សព្វផ្សាយដល់អ្នកដែលពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី២៖ ស្វែងរកការងារជូននិស្សិត** ជាយុទ្ធសាស្ត្រមួយដែលសាកលវិទ្យាល័យបានអនុវត្តកន្លងមក និងធ្លាប់ទទួលបានជោគជ័យតាមរយៈការចុះកិច្ចសហប្រតិបត្តិការ រវាងសាកលវិទ្យាល័យជាមួយបណ្តាក្រុមហ៊ុន អង្គការ និងគ្រឹះស្ថាននានាទាំងផ្នែករដ្ឋនិងឯកជន ដើម្បីផ្តល់ឱកាសដល់និស្សិតគ្រប់រូបត្រៀមលក្ខណៈរបស់ខ្លួនក្នុងស្វែងរកការងារធ្វើ។ ជាពិសេសសាកលវិទ្យាល័យតែងតែបានយកចិត្តទុកដាក់ទៅលើការជម្រុញឱ្យនិស្សិតបានចុះកម្មសិក្សាស្ម័គ្រចិត្តដើម្បីដកស្រង់បទពិសោធន៍ការងារជាក់ស្តែង។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ផ្សព្វផ្សាយដំណឹងស្តីពីការជ្រើសរើសបុគ្គលិករបស់ស្ថាប័ននានា
- សកម្មភាពទី២៖ បង្កើតទំនាក់ទំនង និងស្វែងរកទីកន្លែងសម្រាប់និស្សិតចុះកម្មសិក្សា និងធ្វើការងារ

**យុទ្ធសាស្ត្រទី៣៖ តាមដាន និងគ្រប់គ្រងនិស្សិតមានការងារធ្វើ** ជាយុទ្ធសាស្ត្រដែលធ្វើឲ្យសាកលវិទ្យាល័យឃើញច្បាស់លើលទ្ធផលនៃការផលិត ធនធានមនុស្សរបស់ខ្លួនលើតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន និងពេលអនាគត។ ម៉្យាងវិញទៀតការគ្រប់គ្រងនិស្សិតមានការងារធ្វើបានច្បាស់លាស់ គឺជាភាពជោគជ័យមួយរបស់សាកលវិទ្យាល័យ នៅក្នុងការបណ្តុះបណ្តាលនិស្សិត និងជួយជម្រុញឱ្យសាកលវិទ្យាល័យកាន់តែមាន

ភាពល្បីល្បាញថែមទៀត។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ ជម្រុញឱ្យនិស្សិតបំពេញពត៌មានស្តីពីការងាររបស់ខ្លួន (និស្សិតកំពុងរៀន)
- សកម្មភាពទី២៖ ផ្សព្វផ្សាយឱ្យនិស្សិតចុះតាមគេហទំព័ររបស់សាកលវិទ្យាល័យ
- សកម្មភាពទី៣៖ ជម្រុញឱ្យនិស្សិតបំពេញនៅពេលដែលបញ្ចប់ការសិក្សា

**៦- គោលបំណងទី៦៖ សម្ភារៈសិក្សា និង សម្ភារៈរូបវ័ន្តគ្រប់គ្រាន់** ដើម្បីឲ្យគោលបំណងមួយនេះ សម្រេចនឹងទទួលបានជោគជ័យ នឹងមានដំណើរការល្អវាជារឿងចាំបាច់បំផុត ដែលសាកលវិទ្យាល័យ ត្រូវអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តថ្មីៗ ដែលការពារសុវត្ថិភាព សន្តិសុខ និងភាពងាយស្រួលដល់និស្សិត។ ជាពិសេសការមានសម្ភារៈសិក្សាគ្រប់គ្រាន់នេះ នឹងបម្រើផលប្រយោជន៍យ៉ាងច្រើនឲ្យបុគ្គលិក សាស្ត្រាចារ្យ និង និស្សិតក្នុងការអនុវត្តការងារ ការបង្រៀន និងការសិក្សារៀនសូត្រ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាកលវិទ្យាល័យ បានរៀបចំនូវយុទ្ធសាស្ត្រ និង សកម្មភាពជាច្រើនដើម្បីអនុវត្តដូចខាងក្រោមនេះ៖

**យុទ្ធសាស្ត្រទី១៖ ធ្វើទំនើបកម្មបន្ទប់សិក្សា** ជាយុទ្ធសាស្ត្រមួយ ដែលជម្រុញឲ្យសាកលវិទ្យាល័យខិតខំប្រឹងប្រែងបន្ថែមទៀតលើដំណើរការអភិវឌ្ឍអាគារ និង បន្ទប់សិក្សាឲ្យរឹតតែមានភាព ទាក់ទាញសម្រាប់និស្សិត និង ភ្ញៀវនានាដែលធ្វើទស្សនកិច្ចស្វែងយល់ ពីសាកលវិទ្យាល័យទាំងមូល ។ កត្តាដែល សំខាន់ជាងគេនោះ គឺបំពេញទៅលើតម្រូវការរបស់និស្សិត ដែលទាមទារឱ្យមានសម្ភារៈទាន់សម័យ ក្នុងការជម្រុញឱ្យមានភាពងាយស្រួលលើការបង្រៀន និងការរៀន។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បំពាក់ LCD ឱ្យបាន១០០ភាគរយនៅតាមថ្នាក់រៀននីមួយៗ
- សកម្មភាពទី២៖ បំពាក់ក្តាខៀនកញ្ចក់ ដើម្បីបង្កភាពងាយស្រួលដល់សាស្ត្រាចារ្យ
- សកម្មភាពទី៣៖ បំពាក់ម៉ាស៊ីនត្រជាក់ឱ្យបាន៣៥ភាគរយនៃចំនួនបន្ទប់សរុប

**យុទ្ធសាស្ត្រទី២៖ រៀបចំផែនការគ្រប់គ្រងសម្ភាររូបវន្ត ការអភិវឌ្ឍ និងការជួសជុល** ជាដំណើរការប្រតិបត្តិមួយ ដ៏សំខាន់ក្នុងការធានាបាននូវការរៀបចំផែនការប្រើប្រាស់នូវសម្ភារៈរូបវន្តនានា ប្រកបដោយ ប្រពលភាព និងអាចទុកចិត្តបានក្នុងការផ្តល់នូវសេវាកម្មសិក្សាដល់និស្សិត។ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតគោលការណ៍គ្រប់គ្រងសម្ភារៈ
- សកម្មភាពទី២៖ ថែរក្សា និងជួសជុលសម្ភារៈ

**យុទ្ធសាស្ត្រទី៣៖ គ្រប់គ្រងបណ្ណាល័យ** ជាយុទ្ធសាស្ត្រមួយដែលជម្រុញឲ្យនិស្សិតទាំងអស់ប្រើប្រាស់បណ្ណាល័យជាកន្លែងផ្តល់ចំណេះដឹងដល់ពួកគេតាមរយៈការសិក្សាស្រាវជ្រាវ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតបទបញ្ជាបណ្ណាល័យ

- ○ សកម្មភាពទី២៖ រៀបចំសៀវភៅតាមមហាវិទ្យាល័យ និងមានបិតកូតសម្គាល់
- ○ សកម្មភាពទី៣៖ បង្កើនចំនួនសៀវភៅក្នុងបណ្ណាល័យ១៥ភាគរយ
- ○ សកម្មភាពទី៤៖ គ្រប់គ្រងការខ្ចីសៀវភៅ ការចូលអាន និងការប្រើប្រាស់អ៊ីនធឺណែត

**យុទ្ធសាស្ត្រទី៤៖ សេវាប្រើប្រាស់បន្ទប់អនុវត្ត និងការប្រើប្រាស់អ៊ីនធឺណែត** ជាយុទ្ធសាស្ត្រមួយដែលនឹងជម្រុញឲ្យនិស្សិតទាំងអស់យ៉ាងហោចណាស់ក៏៨០ភាគរយ ចេះប្រើប្រាស់កុំព្យូទ័រដូចជាកិច្ចការរដ្ឋបាល ការរៀបចំឯកសារទិន្នន័យ ជាពិសេសនិស្សិតអាចចេះស្វែងរកព័ត៌មានតាមរយៈបណ្ដាញប្រព័ន្ធអ៊ីនធឺណែត។ ម្យ៉ាងវិញទៀតការចូលអនុវត្តជាក់ស្ដែងពិតជាបង្ហាញឱ្យនិស្សិតកាន់តែមានចំណេះដឹងបន្ថែមទៀត ពីលើការសិក្សាទ្រឹស្ដីដែលសាស្ត្រាចារ្យបានណែនាំ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- ○ សកម្មភាពទី១៖ បង្កើតបន្ទប់សម្រាប់អនុវត្តភាសា
- ○ សកម្មភាពទី២៖ បង្កើតបន្ទប់អនុវត្តកុំព្យូទ័រ
- ○ សកម្មភាពទី៣៖ បំពាក់កុំព្យូទ័រមានភ្ជាប់អ៊ីនធឺណែត បំពាក់ WiFi ក្នុងបរិវេណសាកលវិទ្យាល័យ

**៧- គោលបំណងទី៧៖ អភិវឌ្ឍការស្រាវជ្រាវ** កិច្ចការស្រាវជ្រាវ ជាគោលបំណងមួយដែលមានប្រភពជាក់លាក់ និង ប្រាកដប្រាជានិយម ពីព្រោះការសិក្សាជ្រាវស្រាវ ធ្វើឲ្យនិស្សិត រកឃើញនូវ ប្រភពបញ្ហា ការកំណត់នូវបញ្ហា និង ការដោះស្រាយនូវបញ្ហា ។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវលើ វិស័យសេដ្ឋកិច្ច និង វិទ្យាសាស្ត្រសង្គម អាចជាមាត្រដ្ឋានមួយច្បាស់លាស់ ក្នុងការវាស់វែង ចំណេះដឹង និងសមត្ថភាពរបស់និស្សិតដែលកំពុងតែសិក្សានិងក្រោយពីបញ្ចប់ការសិក្សា។ ដើម្បីឲ្យ គោលបំណងនេះសម្រេចបានស្របតាមទស្សនវិស័យ និងបេសកកម្មរបស់ខ្លួន ធនធានឯកសារនិងសាស្ត្រាចារ្យ ជាជំនួយមួយយ៉ាងសំខាន់ក្នុងការស្វែងរកប្រភពព័ត៌មាន និង ជាភស្តុតាងដែលបង្ហាញពីទឡ្ហីករណ៍ទាក់ទង ទៅនឹងដែនកំណត់ប្រធានបទមួយ អាចយកជាការណ៍បានសម្រាប់និស្សិតជំនាន់ក្រោយទៀត យកមកធ្វើជា លំអានសិក្សាស្រាវជ្រាវ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាកលវិទ្យាល័យ បានរៀបចំនូវយុទ្ធសាស្ត្រ និង សកម្មភាពជាច្រើនដើម្បីអនុវត្តដូចខាងក្រោមនេះ៖

**យុទ្ធសាស្ត្រទី១៖ សមត្ថភាពស្រាវជ្រាវ** ជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់ ដើម្បីឲ្យអ្នកសិក្សាទាំងឡាយយល់កាន់តែច្បាស់ពីរបៀបប្រមូលព័ត៌មាន វិភាគព័ត៌មាន និង សន្និដ្ឋានលើលទ្ធផលដែលខ្លួនទទួលបានតាម រយៈការសិក្សាស្រាវជ្រាវ។ លើសពីនេះទៅទៀត និស្សិតនឹងចេះចាំពីរបៀបធ្វើការស្រាវជ្រាវបែបប្រៀបធៀបក៏ដូចជាវិភាគលើទ្រឹស្ដីជាមួយ នឹងស្ថានភាពជាក់ ស្ដែងប្រកបដោយចំណេះដឹងនិងវិចារណញ្ញាណខ្ពស់។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវយុទ្ធសាស្ត្ររង មួយចំនួនដូចខាងក្រោម៖

- **យុទ្ធសាស្ត្ររងទី១៖** បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមស្រាវជ្រាវ គឺជាយុទ្ធសាស្ត្ររងមួយដែលត្រូវធ្វើជាប្រចាំដើម្បីត្រួតពិនិត្យសកម្មភាពស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវ និងបង្កើនចំនួនក្រុមស្រាវជ្រាវ ក្នុងការ

ផ្តល់ជូននូវពត៌មានបច្ចុប្បន្នលម្អិត និងផែនការអភិវឌ្ឍន៍ធនធានមនុស្ស។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតការិយាល័យ ឫផ្នែកសម្រាប់ប្រមូលផ្តុំធនធានមនុស្សផ្នែកស្រាវជ្រាវ
- សកម្មភាពទី២៖ ប្រមូលជាប្រចាំនូវពត៌មានលម្អិតស្តីពីអ្នកស្រាវជ្រាវ

▪ **យុទ្ធសាស្រ្តរងទី២៖ កំណត់វិស័យអាទិភាពសម្រាប់ការស្រាវជ្រាវ** គឺជាយុទ្ធសាស្រ្តរងមួយដែលសាកលវិទ្យាល័យត្រូវរៀបចំផែនការសកម្មភាពស្រាវជ្រាវ ដើម្បីបំប្លែងតម្រូវការការរបស់សេដ្ឋកិច្ចសង្គម ទៅជាប្រធានបទស្រាវជ្រាវដែលមានសក្តានុពល។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ បង្កើតក្រុមការងារជំនាញដើម្បីពិនិត្យលើវិស័យអាទិភាព
- សកម្មភាពទី២៖ ក្រុមការងារជំនាញប្រជុំជាប្រចាំដើម្បីកំណត់វិស័យអាទិភាពសម្រាប់សកម្មភាពស្រាវជ្រាវ

▪ **យុទ្ធសាស្រ្តរងទី៣៖ អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ** ជាយុទ្ធសាស្រ្តរងមួយដែលសាកលវិទ្យាល័យត្រូវខិតខំធ្វើការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវដល់បុគ្គលិក សាស្រ្តាចារ្យ និងនិស្សិតក្នុងការរៀបចំផែនការ និងដឹកនាំការស្រាវជ្រាវក្នុងវិស័យអាទិភាពប្រកបដោយគុណភាព។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ សិក្សាពីតម្រូវការនៃសមត្ថភាពភាសាអង់គ្លេស ជំនាញសរសេរគម្រោង.
- សកម្មភាពទី២៖ រៀបចំផែនការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវ
- សកម្មភាពទី៣៖ រៀបចំបណ្តុះបណ្តាល និងកសាងសមត្ថភាពអ្នកស្រាវជ្រាវ

**យុទ្ធសាស្រ្តទី២៖ គុណភាពស្រាវជ្រាវ** គឺជាការចាំបាច់សម្រាប់ការស្រាវជ្រាវដែលទាមទារឱ្យសាកលវិទ្យាល័យត្រូវការនូវធនធានមនុស្ស សម្ភារៈ និងមជ្ឈដ្ឋានខាងក្រៅមានគ្រប់គ្រាន់ មិនតែប៉ុណ្ណោះការស្រាវជ្រាវដែលល្អគឺនាំមកនូវផលប្រយោជន៍ជូនសង្គមជាតិ ដែលអាចជួយនៅក្នុងកិច្ចការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ច។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវយុទ្ធសាស្រ្តរង មួយចំនួនដូចខាងក្រោម៖

▪ **យុទ្ធសាស្រ្តរងទី១៖ លើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យបង្ហាញអត្ថបទស្រាវជ្រាវ** គឺជាយុទ្ធសាស្រ្តដែលមិនអាចខ្វះបាន ពីព្រោះការជម្រុញឱ្យបុគ្គលិក សាស្រ្តាចារ្យ និងនិស្សិតខិតខំស្រាវជ្រាវលើប្រធានបទណាមួយនោះ វាទាមទារឱ្យមានការផ្តល់ជូននូវការលើកទឹកចិត្តផ្សេងៗ។ ការលើកទឹកចិត្តគឺជាកម្លាំងចលករមួយដែលធ្វើឱ្យបានសម្រេចនូវគោលបំណងទាំងឡាយ។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖

- សកម្មភាពទី១៖ រៀបចំគោលការណ៍លើកទឹកចិត្តដល់អ្នកស្រាវជ្រាវ

- **យុទ្ធសាស្ត្ររងទី២៖ ជម្រុញអ្នកស្រាវជ្រាវឱ្យសិក្សាប្រធានបទដែលទាក់ទង នឹងការអភិវឌ្ឍសង្គមជាតិ** គឺជាយុទ្ធសាស្ត្រមួយដែលមានសារៈសំខាន់ចំពោះសាកលវិទ្យាល័យ និងសង្គមជាតិ។ដូចនេះអ្នកសិក្សាស្រាវជ្រាវ គប្បីត្រូវស្រាវជ្រាវនូវប្រធានបទទាំងឡាយណាដែលទាក់ទងនឹងសង្គម ដើម្បីទទួលបានលទ្ធផលដែលអាចធ្វើការផ្សព្វផ្សាយដល់ស្ថាប័ន សហគមន៍ និងអ្នកដែលពាក់ព័ន្ធ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖
  - សកម្មភាពទី១៖ រៀបចំគោលការណ៍ដើម្បីផ្តល់អាទិភាពខ្ពស់ និងលទ្ធភាពដល់អ្នកស្រាវជ្រាវដែលធ្វើការស្រាវជ្រាវមានសារៈសំខាន់ចំពោះការអភិវឌ្ឍសង្គមជាតិ
  - សកម្មភាពទី២៖ រៀបចំគោលការណ៍ដើម្បីលើកទឹកចិត្តដល់អ្នកស្រាវជ្រាវឱ្យបោះពុម្ពផ្សាយ
- **យុទ្ធសាស្ត្ររងទី៣៖ ការបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវ** គឺជាការបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវជាសាធារណៈអំពីស្នាដៃដែលក្រុមអ្នកស្រាវជ្រាវបានរកឃើញ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖
  - សកម្មភាពទី១៖ បង្កើតគណៈកម្មការរៀបចំចងក្រង ពិនិត្យ និងបោះពុម្ពផ្សាយ
  - សកម្មភាពទី២៖ បោះពុម្ពផ្សាយជាទស្សនាវដ្តីស្រាវជ្រាវនូវស្នាដៃរបស់អ្នកស្រាវជ្រាវ

**យុទ្ធសាស្ត្រទី៣៖ របាយការណ៍ស្រាវជ្រាវ** គឺជាយុទ្ធសាស្ត្រមួយដែលមិនអាចខ្វះបានទេ ដែលអ្នកសិក្សាស្រាវជ្រាវត្រូវតែធ្វើការបង្ហាញយ៉ាងទូលំទូលាយ នៅតាមវេទិកា សិក្ខាសាលា និងការបោះពុម្ពផ្សាយអំពីបញ្ហាដែលបានរកឃើញ និងដំណោះស្រាយ ដើម្បីឱ្យស្ថាប័ន សហគមន៍ចូលរួមក្នុងការដោះស្រាយ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវយុទ្ធសាស្ត្ររង មួយចំនួនដូចខាងក្រោម៖

- **យុទ្ធសាស្ត្ររងទី១៖ បង្កើតយន្តការ និងវប្បធម៌នៃការធ្វើរបាយការណ៍លទ្ធផលស្រាវជ្រាវ** យុទ្ធសាស្ត្ររងមួយនេះមានន័យថារាល់លទ្ធផលនៃការស្រាវជ្រាវត្រូវបានធ្វើរបាយការណ៍ និងធ្វើបទបង្ហាញជាសាធារណៈ នៅតាមសន្និសីទ វេទិកា និងបោះពុម្ពក្នុងទស្សនាវដ្តីស្រាវជ្រាវ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖
  - សកម្មភាពទី១៖ រៀបចំ និងបើកអង្គប្រជុំស្តីពីកិច្ចការស្រាវជ្រាវ និងរាយការណ៍ពីលទ្ធផល
  - សកម្មភាពទី២៖ បង្កើតទម្រង់ និងគម្រូនៃរបៀបសរសេររបាយការណ៍ស្រាវជ្រាវ
- **យុទ្ធសាស្ត្ររងទី២៖ ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យស្រាវជ្រាវ** គឺជាយុទ្ធសាស្ត្ររងមួយដែលសាកលវិទ្យាល័យត្រូវបង្កើតឡើងដើម្បីងាយស្រួលក្នុងការស្វែងរកពត៌មាន និងធ្វើការស្រាវជ្រាវបានយ៉ាងទូលំទូលាយសម្រាប់អ្នកស្រាវជ្រាវ បុគ្គលិកសិក្សា និស្សិត និងសាធារណៈជន។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យ បានកំណត់នូវសកម្មភាព មួយចំនួនដូចខាងក្រោម៖
  - សកម្មភាពទី១៖ បង្កើតការិយាល័យ ឬផ្នែកដើម្បីរក្សាទុកទិន្នន័យគ្រប់គ្រងការស្រាវជ្រាវ
  - សកម្មភាពទី២៖ ជ្រើសរើសបុគ្គលិកដើម្បីថែរក្សា និងទុកទិន្នន័យគ្រប់គ្រងការស្រាវជ្រាវ

## IV- សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្រ្តរយៈពេល ៣ឆ្នាំនេះផ្តល់នូវទិសដៅមួយចំនួនដែលមានសក្តានុពល ធ្វើឱ្យសាកលវិទ្យាល័យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើងជាលំដាប់។ យើងជឿជាក់ថាតាមរយៈផែនការសកម្មភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តនេះនឹងជួយឱ្យសាកលវិទ្យាល័យសម្រេចនូវជោគជ័យ ដែលបង្ហាញ ឱ្យឃើញពីភាពប៉ិនប្រសប់របស់ថ្នាក់ដឹកនាំ បុគ្គលិក សាស្រ្តាចារ្យ និងនិស្សិតក្នុងការរួមចំណែកអភិវឌ្ឍន៍ និងចែករំលែកនូវចំណេះដឹងឱ្យទូលំទូលាយថែមទៀត។ ផែនការយុទ្ធសាស្រ្តនេះ ជម្រុញឱ្យសហគមន៍ទាំងមូលចូលរួមផងដែរដើម្បីសម្រេចឱ្យបាននូវលទ្ធផលខ្ពស់។ ដើម្បីសម្រេច ឲ្យបាននូវផែនការយុទ្ធសាស្រ្តនេះ សាកលវិទ្យាល័យ ប្តេជ្ញានឹងខិតខំប្រឹងប្រែងអនុវត្ត ដោយលើផ្នែកលើភារកិច្ចទទួលខុសត្រូវទៅតាមផ្នែកនីមួយៗ ពីព្រោះផែនការយុទ្ធសាស្រ្តនេះជាមគ្គុទេសន៍មួយដ៏សំខាន់សម្រាប់ទិសដៅអភិវឌ្ឍន៍សាកលវិទ្យាល័យទាំងមូល។

បាត់ដំបង ថ្ងៃទី.............ខែ................ឆ្នាំ២០...

**ប្រធានក្រុមប្រឹក្សាភិបាល**